**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ ១២.1154/01 គ.ជ.ប

| គណបក្ស សម រង្ស៊ី | |
|---|---|
| នាយកដ្ឋាន រដ្ឋបាល | |
| ចូល | លេខ......197...... |
| | ថ្ងៃទី 14.12 01 |
| | ម៉ោង......8h20... |

# សេចក្តីណែនាំ

## ស្តីពី

## ការរៀបចំអង្គប្រជុំប្រចាំសប្តាហ៍ ដើម្បីពង្រឹងការធានាសន្តិសុខ ពីបច្ចុប្បន្នរហូតដល់ថ្ងៃបោះឆ្នោត

ដើម្បីការពារ និងដោះស្រាយបាតុភាពនានាដែលអាចនឹងកើតមានឡើង ក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ_សង្កាត់ នាពេលខាងមុខ រវាងអាជ្ញាធរមូលដ្ឋាន និងគណបក្សនយោបាយ និងដើម្បីបង្កើនការយោគយល់គ្នាឱ្យកាន់តែល្អប្រសើរ ឡើងរវាងគណបក្សនយោបាយទាំងអស់ ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ_សង្កាត់ នាពេលខាងមុខ ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមធ្វើការណែនាំដល់គណៈកម្មការខេត្ត_ក្រុង រៀបចំការបោះឆ្នោត ទាំងអស់ឱ្យបានជ្រាបថា គណៈកម្មការខេត្ត_ក្រុង រៀបចំការបោះឆ្នោតទាំងអស់ ត្រូវរៀបចំកិច្ចប្រជុំមួយ ឬពីរសប្តាហ៍ម្តងតាមការចាំបាច់ អង្គប្រជុំ គប្បីមានសមាសភាពដូចខាងក្រោម ÷

១_ប្រធាន គខ.កប : ជាប្រធាន
២_សមាជិកដទៃទៀត នៃអនុគណៈកម្មការ
សន្តិសុខខេត្ត_ក្រុង : ជាសមាជិក
៣_តំណាងគ្រប់គណបក្សដែលមានបេក្ខជនឈរឈ្មោះ
បោះឆ្នោត : ជាសមាជិក
៤_តំណាង "គស" : ជាសមាជិក
៥_តំណាងការិយាល័យសិទ្ធិមនុស្សប្រចាំខេត្ត_ក្រុង ទាំងអស់: ជាសមាជិក
៦_អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ : ជាសមាជិក

ទទួលបាននូវសេចក្តីណែនាំនេះ សូមលោក_លោកស្រីប្រធានគណៈកម្មការខេត្ត_ក្រុងរៀបចំការបោះឆ្នោត យកចិត្តទុកដាក់អនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។ 

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ១២ ឆ្នាំ២០០១

ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

ព្រឹទ្ធាចារ្យ ឆេង _ ផុន